KNOW YOUR rights

公益財団法人 橋本財団

Societas Research Institute
ソシエタス総合研究所



សម្រាប់និយោជិតជនបរទេស

# ស្វែងយល់អំពីសិទ្ធិរបស់អ្នក

日本語, English, 中文, 한국어, မြန်မာဘာသာ,
Indonesian, Português, Tiếng Việt, ភាសាខ្មែរ

- ច្បាប់នៃប្រទេសជប៉ុននឹងការពារសិទ្ធិរបស់អ្នកក្នុងនាមជានិយោជិត ទោះជាអ្នកមានសញ្ជាតិឬលក្ខណៈសម្បត្តិស្នាក់នៅអ្វីក៏ដោយ។ ច្បាប់នេះក៏អនុវត្តចំពោះករណីអ្នកបានបាត់បង់លក្ខណៈសម្បត្តិស្នាក់នៅហើយផងដែរ

- ខិតប័ណ្ណនេះត្រូវបានបង្កើតឡើងដោយ Societas Research Institute នៃ Hashimoto Foundation នៅខេត្តអុកាយ៉ាម៉ា ក្រោមកិច្ចសហការជាមួយនឹងសហជីពហ្វុគុយ៉ាម៉ាតាំប៉ុប៉ុ (Fukuyama Union Tanpopo) នៅខេត្តហ៊ីរ៉ូស៊ីម៉ា និង ការិយាល័យច្បាប់សាធារណៈអុកាយ៉ាម៉ា (Okayama Public Law Office) នៅខេត្តអុកាយ៉ាម៉ា។ ប្រសិនបើអ្នកមានសំណួរទាក់ទងនឹងខិតប័ណ្ណនេះ សូមទំនាក់ទំនងសាកសួរមកកាន់យើងខ្ញុំ។



# សូមអ្នកស្វែងយល់អំពីសិទ្ធិនៃនិយោជិតនិងព័ត៌មានជំនួយគាំទ្រនានាដើម្បីប្រើប្រាស់ជាប្រយោជន៍

ខិតប័ណ្ណនេះនឹងពន្យល់ក្នុងលក្ខណៈងាយស្រួលយល់ទាក់ទងនឹងសិទ្ធិរបស់និយោជិតដែលត្រូវបានការពារដោយច្បាប់។ ប្រសិនបើនៅកន្លែងការងារ អ្នកមានអារម្មណ៍ថាមិនទទួលបានការការពារសិទ្ធិទេ សូមអ្នកទាក់ទងទៅកាន់បញ្ជរពិគ្រោះដែលបង្ហាញនៅខាងក្រោយខិតប័ណ្ណនេះ។

## 1 កិច្ចសន្យាការងារ
koyō keiyakusho

**សូមអ្នកពិនិត្យខ្លឹមសារ មុននឹងចុះហត្ថលេខានៅលើកិច្ចសន្យាការងារ**

**សូមអ្នករក្សាទុកកិច្ចសន្យាការងារដោយខ្លួនឯង**

ក្រុមហ៊ុនត្រូវបានតម្រូវឱ្យប្រើប្រាស់ភាសាកំណើតរបស់អ្នកបើអាចធ្វើបាន នៅក្នុងការផ្តល់កិច្ចសន្យាការងារដល់អ្នក* នៅក្នុងកិច្ចសន្យាការងារគឺមានបញ្ជាក់អំពីខ្លឹមសារលម្អិតទាក់ទងនឹងលក្ខខណ្ឌការងារ (ឧទាហរណ៍ ប្រាក់ឈ្នួល រយៈពេលធ្វើការ លក្ខខណ្ឌការងារ)។ ម្យ៉ាងទៀត សូមអ្នកពិនិត្យមើលបទប្បញ្ញត្តិការងារផងដែរ។

>> កិច្ចសន្យាការងារគឺជាឯកសារព្រមព្រៀងដែលបញ្ជាក់យ៉ាងច្បាស់អំពីសិទ្ធិនិងទំនួលខុសត្រូវរបស់អ្នកក្នុងនាមជានិយោជិត។ នៅពេលចាប់ផ្តើមការងារថ្មី និយោជកចាំបាច់ត្រូវផ្តល់ឯកសារដែលបញ្ជាក់លម្អិតអំពីលក្ខខណ្ឌការងាររបស់អ្នក។ *ករណីគ្មានការបកប្រែខ្លឹមសារនៅក្នុងកិច្ចសន្យាការងារឬបទប្បញ្ញត្តិការងារទេ សូមអ្នកពិនិត្យខ្លឹមសារទាំងនោះជាមួយអ្នកដែលអាចអានភាសាជប៉ុនបាន។

## 2 ប្រាក់ខែ និង ប្រាក់ឈ្នួល
kyūyo・kyūryō

**តើអ្នកទទួលបានប្រាក់ឈ្នួលចាប់ពីកម្រិតប្រាក់ឈ្នួលអប្បបរមាឡើងទៅដែរឬទេ? ***

**តើអ្នកទទួលបានប្រាក់ឈ្នួលដោយផ្ទាល់ម្តងជារៀងរាល់ខែដែរឬទេ?**

ប្រាក់ឈ្នួលចាំបាច់ត្រូវបង់ជូនអ្នកដោយផ្ទាល់ (តាមរយៈការប្រគល់ប្រាក់សុទ្ធ ឬ ការបង់តាមគណនីធនាគារ)។ ប្រាក់ឈ្នួលចាំបាច់ត្រូវបង់ជូនអ្នកយ៉ាងហោចណាស់1ដងក្នុង1ខែនៅថ្ងៃដែលបានកំណត់នៅក្នុងកិច្ចសន្យាការងារ។

>> កម្រិតប្រាក់ឈ្នួលអប្បបរមា សំដៅទៅលើចំនួនទឹកប្រាក់អប្បបរមាដែលក្រុមហ៊ុនត្រូវបង់ជូននិយោជិត ដោយគណនាជាប្រាក់ម៉ោង។ ចំនួនទឹកប្រាក់នោះអាចខុសគ្នាទៅតាមតំបន់ឬប្រភេទឧស្សាហកម្ម។ បើមានភាពខុសគ្នារវាងកម្រិតប្រាក់ឈ្នួលអប្បបរមាតាមតំបន់និងកម្រិតប្រាក់ឈ្នួលអប្បបរមាតាមប្រភេទអាជីវកម្ម គឺត្រូវកំណត់យកចំនួនទឹកប្រាក់ដែលមានកម្រិតខ្ពស់ជាង។
*គិតត្រឹមខែតុលា ឆ្នាំ2025 កម្រិតប្រាក់ឈ្នួលអប្បបរមានៅខេត្តអ៊ុកាយ៉ាម៉ាគឺ 1,047 យេន។

## 3 ឯកសារលម្អិតខ្លឹមសារប្រាក់ឈ្នួល
kyūyo meisai-sho

**សូមអ្នកទទួលយកឯកសារលម្អិតខ្លឹមសារប្រាក់ឈ្នួល* ហើយពិនិត្យថាតើមានកំហុសណាមួយដែរឬទេ សូមអ្នករក្សាទុកឯកសារលម្អិតខ្លឹមសារប្រាក់ឈ្នួលនោះ។**

ប្រសិនបើមានការកាត់កងប្រាក់ពីប្រាក់ឈ្នួលរបស់អ្នកលើសពីភាពចាំបាច់ សូមកុំរារែកនៅក្នុងការពិគ្រោះជាមួយនរណារម្នាក់។

>> នៅក្នុងឯកសារលម្អិតខ្លឹមសារប្រាក់ឈ្នួល គឺមានបង្ហាញអំពីចំនួនទឹកប្រាក់ដែលត្រូវបង់និងចំនួនទឹកប្រាក់ដែលត្រូវកាត់កង(ដកចេញ)ដោយនិយោជក។ យោងទៅតាមច្បាប់ ក្រុមហ៊ុនអាចកាត់កងត្រឹមតែចំនួនទឹកប្រាក់ដែលបានបញ្ជាក់ច្បាស់លាស់នៅក្នុងកិច្ចសន្យាការងារ(ហើយមានការយល់ព្រមពីអ្នក)ប៉ុណ្ណោះ រួមមានដូចជា ប្រាក់ពន្ធ ប្រាក់ធានារ៉ាប់រង ជាដើម។ *ក្រុមហ៊ុនមានកាតព្វកិច្ចផ្តល់ឯកសារលម្អិតខ្លឹមសារប្រាក់ឈ្នួល (ទម្រង់ជាក្រដាសឬជាទិន្នន័យ) ស្របពេលនឹងការបង់ប្រាក់ឈ្នួល។

## 4 ការធ្វើការងារថែមម៉ោង
zangyō

### ការណីអ្នកបានធ្វើការងារថែមម៉ោង តើអ្នកបានទទួលប្រាក់ឈ្នួលសម្រាប់ការងារថែមម៉ោងនោះដែរឬទេ?
### សូមអ្នកកត់ត្រាអំពីរយៈពេលដែលអ្នកបានធ្វើការងារ

ករណីអ្នកបានធ្វើការថែមម៉ោងឬបានធ្វើការនៅវេលាយប់ឬថ្ងៃឈប់សម្រាក អ្នកមានសិទ្ធិទទួលបានប្រាក់ឈ្នួលរួមជាមួយប្រាក់ឧបត្ថម្ភ។ ទៅតាមស្ថានភាព អ្នកអាចទទួលបានប្រាក់ឈ្នួលរួមជាមួយប្រាក់ឧបត្ថម្ភ ស្មើនឹង 1.25 ទៅ 1.75 ដងនៃប្រាក់ម៉ោងធម្មតា។

» ករណីអ្នកបានធ្វើការលើសពីរយៈពេលធ្វើការធម្មតាដែលកំណត់ដោយច្បាប់(1ថ្ងៃ8ម៉ោង 1សប្តាហ៍40ម៉ោង) នោះនឹងត្រូវបានចាត់ទុកថាអ្នកបានធ្វើការថែមម៉ោង។ ករណីក្រុមហ៊ុនបានទាមទារឱ្យអ្នកធ្វើការលើសពីការកំណត់នេះ ឬ បានទាមទារឱ្យអ្នកធ្វើការនៅវេលាយប់ឬថ្ងៃឈប់សម្រាក នោះគឺត្រូវបានចាត់ទុកថាជាការធ្វើការថែមម៉ោង។

## 5 ការឈប់សម្រាក់ដោយមានប្រាក់ឈ្នួល
yūkyū kyūka

### ករណីអ្នកបានបន្តធ្វើការងារបច្ចុប្បន្នរយៈពេល6ខែ ហើយមានវត្តមានចាប់ពី80ភាគរយឡើងទៅ នោះអ្នកអាចទទួលបានការឈប់សម្រាកដោយមានប្រាក់ឈ្នួល

នៅពេលសុំឈប់សម្រាកពីការងារ អ្នកមិនចាំបាច់ប្រាប់អំពីហេតុផលទៅក្រុមហ៊ុនទេ។ ក្រុមហ៊ុនមិនត្រូវប្រព្រឹត្តទង្វើអយុត្តិធម៌ចំពោះនិយោជិតដោយសារហេតុផលថានិយោជិតនោះបានស្នើសុំឈប់សម្រាកនោះទេ ប៉ុន្តែ ក្រុមហ៊ុនអាចសុំឱ្យផ្លាស់ប្តូរថ្ងៃឈប់សម្រាកបាន។

» សម្រាប់ការឈប់សម្រាកនៅថ្ងៃបុណ្យជាតិឬថ្ងៃឈប់សម្រាកជាដើម គឺគ្មានឥទ្ធិពលទៅលើប្រាក់ឈ្នួលដូចជាការបង្កើនប្រាក់ឈ្នួលជាដើមនោះឡើយ។ បុគ្គលិកក៏មានសិទ្ធិទទួលបានការឈប់សម្រាកពាក់ព័ន្ធនឹងគ្រួសារ ដូចជា ការឈប់សម្រាកមើលថែទាំកូន ការឈប់សម្រាកសម្រាលកូន ការឈប់សម្រាកដោយសារមរណភាពសាច់ញាតិជាដើម។ សូមអ្នកពិនិត្យខ្លឹមសារនៃបទប្បញ្ញត្តិការងារ។

## 6 ថ្ងៃឈប់សម្រាក
kyūjitsu

### សូមអ្នកពិនិត្យមើលប្រតិទិនរបស់ក្រុមហ៊ុនអំពីថ្ងៃឈប់សម្រាកនិងថ្ងៃបុណ្យជាតិ។

ក្រុមហ៊ុនត្រូវផ្តល់ថ្ងៃឈប់សម្រាកយ៉ាងហោចណាស់1ថ្ងៃរៀងរាល់សប្តាហ៍ ឬ យ៉ាងហោចណាស់4ថ្ងៃក្នុងរយៈពេល4សប្តាហ៍។

» ថ្ងៃឈប់សម្រាក មានន័យថា "ថ្ងៃសម្រាកពីការងារ" គឺសំដៅទៅលើថ្ងៃដែលអ្នកគ្មានកាតព្វកិច្ចធ្វើការងារទេ។ នៅពេលចាប់ផ្តើមចូលធ្វើការ សូមអ្នកពិនិត្យមើលបទប្បញ្ញត្តិការងារនិងប្រតិទិនអំពី"ថ្ងៃឈប់សម្រាក"របស់ក្រុមហ៊ុន។

## 7 ម៉ោងសម្រាក
kyūkei

### តើអ្នកទទួលបានម៉ោងសម្រាក នៅអំឡុងពេលធ្វើការងារដែរឬទេ?

និយោជក ត្រូវផ្តល់ម៉ោងសម្រាក45នាទីករណីម៉ោងធ្វើការក្នុងមួយថ្ងៃមានចំនួន6ម៉ោងឡើងទៅ ហើយត្រូវផ្តល់ម៉ោងសម្រាក1ម៉ោង ករណីម៉ោងធ្វើការក្នុងមួយថ្ងៃមានចំនួន8ម៉ោងឡើងទៅ។

» ម៉ោងសម្រាក គឺសំដៅទៅលើរយៈពេលដែលអ្នកអាចចាកចេញពីកន្លែងធ្វើការនិងឃ្លាតពីសកម្មភាពការងារឬទំនួលខុសត្រូវបាន។ ម៉ោងសម្រាក មិនអាចប្តូរទៅជាប្រាក់ឈ្នួលទេ។

## 8 ការបៀតបៀន
harasumento

សម្រាប់ព័ត៌មានលម្អិត សូមមើលនៅក្នុងឯកសារច្រើនភាសានៃក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព នៃប្រទេសជប៉ុន "អំពីច្បាប់ស្តីពីសមភាព និង ច្បាប់ស្តីពីការបៀតបៀននៅកន្លែងការងារ ការឈប់សម្រាកមើលថែទាំកូន និង ការឈប់សម្រាកមើលថែទាំគ្រួសារ"

### សូមអ្នករក្សាទុកនូវភ័ស្តុតាងនៃអំពើបៀតបៀន* (វត្ថុដែលអាចបញ្ជាក់ថាតើនរណាជាអ្នកប្រព្រឹត្ត ហើយបានប្រព្រឹត្តអ្វី)

សូមអ្នករក្សាទុកនូវវីដេអូឬសម្លេងថត ក៏ដូចជាសារខ្លី(SMS)ឬLINEជាដើមដែលបង្ហាញអំពីការបៀតបៀន។ ច្បាប់ហាមឃាត់មិនអនុញ្ញាតឱ្យក្រុមហ៊ុនប្រព្រឹត្តទង្វើអយុត្តិធម៌ចំពោះអ្នក ដោយសារហេតុផលថាអ្នកបានរាយការណ៍អំពីការបៀតបៀននោះទេ។

>> *ការបៀតបៀន សំដៅមិនត្រឹមតែទៅលើការវាយប្រហារផ្លូវកាយ (ឧទាហរណ៍ ការទាត់ ការវាយ ការទះ ការប៉ះពាល់លក្ខណៈមិនសមរម្យ)និងការវាយប្រហារតាមពាក្យសម្តីឬផ្លូវចិត្ត(ឧទាហរណ៍ ពាក្យសម្តីហិង្សា ការគំរាមកំហែង ពាក្យសម្តីរើសអើង)ប៉ុណ្ណោះទេ ប៉ុន្តែក៏សំដៅទៅលើការគំរាមកំហែងនិងការបង្ខិតបង្ខំផងដែរ។ ប្រសិនបើអ្នកបានទទួលការបៀតបៀន សូមធ្វើការពិគ្រោះបញ្ហានោះឱ្យបានឆាប់រហ័ស។

## 9 ការបញ្ឈប់ការងារ
kaiko

### តើអ្នកត្រូវបានបញ្ឈប់ការងារដោយភ្លាមៗដែរឬទេ? សូមអ្នកទាមទារលិខិតបញ្ជាក់ហេតុផលនៃការបញ្ឈប់ការងារពីក្រុមហ៊ុន

ករណីបញ្ឈប់ការងារ ក្រុមហ៊ុនត្រូវជូនដំណឹងដល់បុគ្គលិកជាមុនយ៉ាងហោចណាស់30ថ្ងៃមុន ឬ ត្រូវបង់ប្រាក់ឈ្នួលសម្រាប់រយៈពេល30ថ្ងៃដល់បុគ្គលិក។ ទោះជាក្រុមហ៊ុនសុំឱ្យអ្នកឈប់ពីការងារ(ណែនាំឱ្យឈប់ពីការងារ)ក៏ដោយ ប្រសិនបើអ្នកនៅចង់បន្តធ្វើការ អ្នកមានសិទ្ធិបន្តធ្វើការងារនោះ។

>> ការបញ្ឈប់ការងារ គឺជាការបញ្ចប់កិច្ចសន្យាការងារពីភាគីក្រុមហ៊ុនតែម្ខាង។ ការបញ្ឈប់ការងារដោយសារហេតុផលដូចជាគ្រោះថ្នាក់ការងារ ការមានផ្ទៃពោះ ការសម្រាលកូនជាដើមគឺត្រូវបានហាមឃាត់ដោយច្បាប់។ អ្នកអាចតវ៉ាចំពោះការបញ្ឈប់ការងារដោយមិនសមហេតុផល។

## 10 ការឈប់ពីការងារ
taishoku

សម្រាប់ព័ត៌មានលម្អិត សូមមើលនៅក្នុងឯកសារច្រើនភាសានៃក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព អំពី "កូនសៀវភៅសម្រាប់អ្នកចាកចេញពីការងារនិងអ្នកមានលក្ខណៈសម្បត្តិទទួលការធានារ៉ាប់រងការងារ"

### និយោជិតមានសេរីភាពក្នុងការឈប់ពីការងារ។ ក្រុមហ៊ុនមិនអាចរារាំងការឈប់ពីការងាររបស់អ្នកបានឡើយ*

វិន័យនៃការឈប់ពីការងារអាចខុសគ្នា ដូច្នេះ សូមអ្នកពិនិត្យមើលនីតិវិធីនៃការឈប់ពីការងាររបស់ក្រុមហ៊ុនអ្នកនៅក្នុងបទប្បញ្ញត្តិការងារឬកិច្ចសន្យាការងារ។ ករណីលក្ខខណ្ឌការងារមានលក្ខណៈខុសពីនៅក្នុងកិច្ចសន្យាការងារ : ករណីអ្នកចង់បន្តធ្វើការងារនោះ សូមអ្នកពិគ្រោះជាមួយស្ថាប័នផ្តល់ជំនួយគាំទ្រ។ ម្យ៉ាងទៀត អ្នកក៏មានសិទ្ធិឈប់ពីការងារនោះផងដែរ។

>> ក្នុងអំឡុងពេល1ខែក្រោយពេលឈប់ពីការងារ សូមអ្នកទទួលឯកសារមួយចំនួនពីក្រុមហ៊ុន ដូចជា 1.ប័ណ្ណធានារ៉ាប់រងការងារ 2.សៀវភៅសោធននិវត្តន៍ 3.ប័ណ្ណពន្ធកាត់ទុក ហើយសម្រាប់អ្នកដែលមិនទាន់កំណត់កន្លែងធ្វើការងារបន្ទាប់ពីនោះ សូមទទួលឯងឯកសារ 4.លិខិតបញ្ជាក់ការចាកចេញពីការងារ។ *ករណីអ្នកចង់ឈប់ពីការងារ ប៉ុន្តែ ក្រុមហ៊ុនមិនអនុញ្ញាតឱ្យអ្នកឈប់ សូមអ្នកស្វែងរកការពិគ្រោះ។

## 11 សហជីពការងារ
rōdō kumiai

### និយោជិតមានសិទ្ធិពិគ្រោះនិងស្នើសុំជំនួយពីសហជីព/សហជីពការងារ*

ច្បាប់ហាមឃាត់មិនឱ្យក្រុមហ៊ុនប្រព្រឹត្តទង្វើអយុត្តិធម៌ ដូចជា ការគំរាមកំហែង ការបញ្ឈប់ពីការងារជាដើមចំពោះអ្នក ដោយសារហេតុផលថាអ្នកបានចូលជាសមាជិកនៃសហជីពការងារនោះទេ។

>> *សហជីព/សហជីពការងារ (Rodo Kumiai) គឺខុសពីសហករណ៍ (Kyodo Kumiai)។ សហជីពការងារគឺជាអង្គភាពឯករាជ្យសម្រាប់និយោជិត។ បើអ្នកមានបញ្ហាជាមួយនឹងក្រុមហ៊ុន អ្នកអាចពិគ្រោះជាមួយសហជីពការងារបាន។

# សូមអ្នកសាកសួរទៅកាន់បញ្ជរពិគ្រោះដោយឥតគិតថ្លៃ

ករណីអ្នកចង់ពិគ្រោះដោយឥតគិតថ្លៃជាមួយនឹងស្ថាប័នរដ្ឋទាក់ទងនឹងបញ្ហាការងារនៅខេត្តអុកាយ៉ាម៉ា សូមទាក់ទងទៅកាន់បញ្ជរពិគ្រោះខាងក្រោម។ បើអ្នកមិនដឹងថាគួរពិគ្រោះនៅទីណា ឬ ចង់មានអ្នកបកប្រែ សូមអ្នកទាក់ទងទៅកាន់មជ្ឈមណ្ឌលទំនាក់ទំនងអន្តរជាតិ។

## មជ្ឈមណ្ឌលទំនាក់ទំនងអន្តរជាតិអុកាយ៉ាម៉ា

នេះគឺជាបញ្ជរជំនួយគាំទ្រជនបរទេសនៃខេត្តអុកាយ៉ាម៉ា ដែលនឹងផ្តល់ជំនួយគាំទ្រដល់អ្នក ករណីអ្នកមិនដឹងថាត្រូវពិភាក្សាជាមួយនឹងស្ថាប័នណា ឬ ករណីអ្នកត្រូវការអ្នកបកប្រែ។ នៅមជ្ឈមណ្ឌលនេះ អ្នកអាចពិភាក្សាដោយប្រើភាសាច្រើន និង ទទួលបានព័ត៌មាននានាដែលចាំបាច់សម្រាប់ការរស់នៅ។ អ្នកអាចពិភាក្សាដោយប្រើភាសាច្រើនតាមរយៈទូរសព្ទឬអ៊ីមែល។

ការពិគ្រោះ 日本語, English, 中文, Português, Tiếng Việt, Tagalog, 한국어, Bahasa Indonesia, ภาษาไทย, नेपाली, Español

**0120-007-173（ភាសាជប៉ុនងាយៗ）**

2-2-1 Hokancho, Kita Ward, Okayama (ថ្ងៃចន្ទ ដល់ ថ្ងៃសៅរ៍: ម៉ោង 9:00-17:00)

## ហេឡូវើកអុកាយ៉ាម៉ា (Hello Work Okayama)

ហេឡូវើក(Hello Work) គឺជាស្ថាប័នរដ្ឋ (ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព)។ អ្នកអាចពិគ្រោះទាក់ទងនឹងការស្វែងរកការងារ នីតិវិធីនៃធានារ៉ាប់រងការងារជាដើម។ ស្ថាប័ននេះនៅក្រុងអុកាយ៉ាម៉ា ក្រុងគុរ៉ាស៊ីគី និង ក្រុងសូចា គឺមានបញ្ជរច្រើនភាសា។ អ្នកអាចពិគ្រោះដោយប្រើភាសាច្រើនផ្សេងគ្នាទៅតាមថ្ងៃធ្វើការ ដូច្នេះ សូមពិនិត្យមើលព័ត៌មានលម្អិតនៅលើគេហទំព័រ។

ការពិគ្រោះ 日本語, ភាសាជប៉ុនងាយៗ, English, Português

**086-241-3701（ភាសាជប៉ុនងាយៗ）**

1-1-20 Noda, Kita Ward, Okayama (ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ: ម៉ោង 8:30-17:15)

## ការិយាល័យត្រួតពិនិត្យបទដ្ឋានការងារ

ការិយាល័យត្រួតពិនិត្យបទដ្ឋានការងារ គឺជាស្ថាប័នរដ្ឋ (ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព)។ អ្នកអាចពិគ្រោះទាក់ទងនឹងខ្លឹមសារ ដូចជា ការមិនទទួលបានការបង់ប្រាក់ឈ្នួលឬប្រាក់ថែមម៉ោង ការធ្វើការថែមម៉ោង ការមិនទទួលបានការឈប់សម្រាកដោយមានប្រាក់ឈ្នួល ការចង់ឈប់ពីការងារ ប៉ុន្តែមិនត្រូវបានអនុញ្ញាឱ្យឈប់ ការត្រូវបានបដិសេធចំពោះការប្រើប្រាស់ធានារ៉ាប់រងការងារ ជាដើម។ល។

ការពិគ្រោះ 日本語, ភាសាជប៉ុនងាយៗ

**086-283-4540（ភាសាជប៉ុនងាយៗ）**

2-11-20 Daiku, Kita Ward, Okayama (ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ: ម៉ោង 8:30-17:15)

## ផ្នែកពិគ្រោះសម្រាប់ជនបរទេសនៃមន្ទីរការងារ

មន្ទីរការងារ គឺជាស្ថាប័នរដ្ឋ (ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព)។ នៅផ្នែកពិគ្រោះសម្រាប់ជនបរទេស អ្នកអាចពិគ្រោះតាមទូរសព្ទទាក់ទងនឹងបញ្ហាការងារ ការបៀតបៀនដោយប្រើអំណាច ការបៀតបៀនផ្លូវភេទ ការបៀតបៀនទាក់ទងនឹងការមានផ្ទៃពោះ ការឈប់សម្រាកមើលថែទាំកូន ការឈប់សម្រាកមើលថែទាំគ្រួសារ ជាដើម។ល។ អ្នកអាចពិគ្រោះដោយប្រើភាសាច្រើនបានទៅតាមថ្ងៃធ្វើការ។ សម្រាប់ព័ត៌មានលម្អិត សូមពិនិត្យមើលនៅលើគេហទំព័រ។

ការពិគ្រោះ 日本語, ភាសាជប៉ុនងាយៗ, English, 中文, Tiếng Việt

**086-201-1651（ភាសាជប៉ុនងាយៗ）**

1-4-1 Shimoishii, Kita Ward, Okayama (ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ: ម៉ោង 9:00-16:30)

ករណីអ្នកចង់ពិគ្រោះដោយឥតគិតថ្លៃជាមួយស្ថាប័នឯកជនទាក់ទងនឹងបញ្ហាការងារ សូមទាក់ទងទៅកាន់បញ្ជរពិគ្រោះខាងក្រោម។

## **សហជីពហ្វុគុយ៉ាម៉ាតាំប៉ុប៉ុ** (Fukuyama Union Tanpopo)

នេះគឺជាសហជីពការងារ(សហជីព)ដែលស្ថិតនៅក្រុងហ្វុគុយ៉ាម៉ា។ អ្នកអាចពិគ្រោះទាក់ទងនឹងការបៀតបៀននៅកន្លែងការងារ ការផ្លាស់ប្ដូរការងារ គ្រោះថ្នាក់ការងារជាដើម។ សហជីពនេះទទួលការពិគ្រោះពីនិយោជិតគ្រប់ទាំងអស់ រួមទាំងនិយោជិតដែលបានបាត់បង់លក្ខណៈសម្បត្តិស្នាក់នៅ(ការស្នាក់នៅលើសកាលកំណត់)ជាដើមផងដែរ។ សូមផ្ញើសារតាមទំព័រហ្វេសប៊ុក

ការផ្ញើសារតាមហ្វេសប៊ុក: 日本語, ភាសាជប៉ុនងាយៗ, 中文, Tiếng Việt, ខ្មែរ, Indonesian, សម្រាប់ភាសាផ្សេងគឺមានការបកប្រែ

**084-928-5055（ភាសាជប៉ុនងាយៗ）/** ការពិគ្រោះបន្ទាន់ 090-2860-4737 (Muto)

fukuyama-u-t@mx71.tiki.ne.jp

4-1-25 Kasumicho, Fukuyama, Hiroshima (បើករាល់ថ្ងៃ, ម៉ោង 10:00 ដល់ 18:00)

## **សហជីពការងារខេត្តអុកាយ៉ាម៉ា**

នេះគឺជាសហជីពការងារ(សហជីព)ដែលស្ថិតនៅខេត្តអុកាយ៉ាម៉ា។ អ្នកអាចពិគ្រោះទាក់ទងនឹងជីវភាពរស់នៅនៃនិយោជិតដែលធ្វើការងារក្នុងតំបន់ ឬបញ្ហាជាមួយនឹងក្រុមហ៊ុនជាដើម។ សហជីពនេះទទួលការពិគ្រោះពីនិយោជិតគ្រប់ទាំងអស់ រួមទាំងនិយោជិតដែលបានបាត់បង់លក្ខណៈសម្បត្តិស្នាក់នៅ(ការស្នាក់នៅលើសកាលកំណត់)ជាដើមផងដែរ។

ការពិគ្រោះ 日本語, ភាសាជប៉ុនងាយៗ, សម្រាប់ភាសាផ្សេងគឺមានការបកប្រែ

**086-221-0133（ភាសាជប៉ុនងាយៗ）**

Okayama Workers Welfare Center 3F 5-6 Kasugacho, Kita-ku, Okayama

## **តើដូចម្ដេចដែលហៅថាសហជីពការងារ/សហជីព?**

"សហជីពគឺជាស្ថាប័នឯករាជ្យ*សម្រាប់និយោជិត ដែលធ្វើសកម្មភាពការពារសិទ្ធិរបស់និយោជិត កែលម្អលក្ខខណ្ឌការងារនិងបរិស្ថាននៅកន្លែងធ្វើការជាដើម។ *សហជីពស្ថិតនៅឯករាជ្យពីស្ថាប័នរដ្ឋ ក្រុមហ៊ុន ស្ថាប័នគ្រប់គ្រង សហករណ៍ ជាដើម។ល។

តើអ្នកអាចពឹងពាក់សហជីពក្នុងករណីដូចម្ដេចខ្លះ? សហជីពនឹងទទួលការពិគ្រោះទាក់ទងនឹងបញ្ហាដែលកើតឡើងនៅក្នុងការធ្វើការងាររបស់អ្នក ដូចជា ការមិនអាចធ្វើការងារដោយស្ងប់ចិត្តបាននៅកន្លែងការងារ ការបៀតបៀនដោយអំណាច ការបៀតបៀនផ្លូវភេទ ការមិនទទួលបានការបង់ប្រាក់ថែមម៉ោងជាដើម ហើយសហជីពនឹងធ្វើការចរចាជាមួយនឹងក្រុមហ៊ុនជំនួសអ្នក។

តើនរណាអាចពិគ្រោះបាន? អ្នកដែលកំពុងធ្វើការងារ ដោយមិនគិតអំពីសញ្ជាតិឬលក្ខណៈសម្បត្តិស្នាក់នៅទេ គឺថានរណាក៏ដោយ ក៏ត្រូវបានធានាចំពោះសិទ្ធិនៅក្នុងការពិគ្រោះ ការចូលជាសមាជិក និង ការស្នើសុំជំនួយពីសហជីពផងដែរ។ ម្យ៉ាងទៀត ច្បាប់ស្ដីពីសហជីពការងារបានហាមឃាត់មិនឱ្យក្រុមហ៊ុនប្រព្រឹត្តទង្វើអយុត្តិធម៌ ដូចជា ការគំរាមកំហែងឬការបញ្ឈប់អ្នកពីការងារ ដោយសារហេតុផលថាអ្នកបានចូលជាសមាជិកនៃសហជីពនោះទេ។"

ករណីអ្នកមានបំណងពិគ្រោះដោយគិតថ្លៃទាក់ទងនឹងបញ្ហាការងារ សូមទាក់ទងទៅកាន់បញ្ជរពិគ្រោះខាងក្រោម។

## **ការិយាល័យច្បាប់សាធារណៈអុកាយ៉ាម៉ា** (Okayama Public Law Office)

នេះគឺជាការិយាល័យច្បាប់ ដែលផ្ដល់ការប្រឹក្សាអំពីច្បាប់ ដោយអ្នកអាចពិគ្រោះទាក់ទងនឹងបញ្ហាដូចជា បំណុល ការងារ គ្រោះថ្នាក់ចរាចរណ៍ ការលែងលះ លក្ខណៈសម្បត្តិស្នាក់នៅជាដើម។ល។ ទោះជាអ្នកគ្មានលក្ខណៈសម្បត្តិស្នាក់នៅ ក៏មិនត្រូវអស់សង្ឃឹមនិងបោះបង់ដែរ។ ថ្លៃពិគ្រោះគឺ5,500យេនសម្រាប់រយៈពេល40នាទី។ សូមធ្វើការណាត់ទុកជាមុន តាមរយៈទូរសព្ទឬការបំពេញទម្រង់ព័ត៌មាននៅលើគេហទំព័រ។

ការពិគ្រោះ 日本語, ភាសាជប៉ុនងាយៗ, សម្រាប់ភាសាផ្សេងគឺមានការបកប្រែ

**086-221-0133（ភាសាជប៉ុនងាយៗ）**

Okayama Workers Welfare Center 2F 5-6 Kasugacho, Kita-ku, Okayama (ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ: ម៉ោង 9:00-18:00)

## សូមស្វែងរកការពិគ្រោះ

"ការស្វែងរកដំបូន្មានឬជំនួយគាំទ្រពីសមត្ថកិច្ចក្នុងតំបន់ ស្ថាប័នស្ម័គ្រចិត្ត ឬសហជីពការងារ គឺជាសិទ្ធិរបស់អ្នក។ ក្រុមហ៊ុនដែលប្រព្រឹត្តទង្វើអយុត្តិធម៌ឬបញ្ឈប់បុគ្គលិកពីការងារដោយសារហេតុផលថាបុគ្គលិកនោះបានស្នើសុំជំនួយទាក់ទងនឹងបញ្ហានៅក្នុងការងារ គឺជាអំពើខុសច្បាប់។

ប្រសិនបើអ្នកមិនទទួលបានការទទួលស្គាល់ទៅលើសិទ្ធិរបស់ខ្លួន ឬក៏ អ្នកមានសំណួរទាក់ទងនឹងកន្លែងការងាររបស់ខ្លួន សូមទាក់ទងទៅកាន់បញ្ជរពិគ្រោះឬស្ថាប័នពិគ្រោះ។

បើអាច សូមពិនិត្យលក្ខណៈសម្បត្តិស្នាក់នៅនិងលិខិតឆ្លងដែនរបស់អ្នកមុននឹងធ្វើការពិគ្រោះ ព្រោះខ្លឹមសារនៃសិទ្ធិនិងវិធីផ្តល់ជំនួយអាចខុសគ្នាទៅតាមលក្ខខណ្ឌដូចជាការមានឬគ្មាន និងប្រភេទនៃលក្ខណៈសម្បត្តិស្នាក់នៅជាដើម។ ប៉ុន្តែ ទោះជាអ្នកគ្មានលក្ខណៈសម្បត្តិស្នាក់នៅក៏ដោយ ក៏មិនត្រូវអស់សង្ឃឹមនិងបោះបង់ដែរ។"





# សូមអ្នកកុំព្រួយបារម្ភតែម្នាក់ឯង សូមស្វែងរកជំនួយណាមួយសម្រាប់ខ្លួនអ្នក

## អ្នកអាចពិគ្រោះទាក់ទងនឹងក្តីបារម្ភដូចខាងក្រោម

- មិនទទួលបានការបង់ប្រាក់ឈ្នួល
- មិនទទួលបានការបង់ប្រាក់ឈ្នួលអប្បបរមា
- មិនទទួលបានការបង់ប្រាក់ថែមម៉ោង
- នៅលើឯកសារលម្អិតខ្លឹមសារប្រាក់ឈ្នួលមិនបានបញ្ជាក់អំពីការកាត់កង
- មិនទទួលបានការឈប់សម្រាកដោយមានប្រាក់ឈ្នួលឬម៉ោងសម្រាកពីការងារ
- ការបៀតបៀនដោយអំណាចឬភាពអយុត្តិធម៌នៅកន្លែងការងារ
- ការបៀតបៀនផ្លូវភេទ
- ការធ្វើបាបនិងការបញ្ឈប់ពីការងារដោយសារការមានផ្ទៃពោះ
- ការបញ្ឈប់ការងារដោយភ្លាមៗ
- ត្រូវបានគំរាមកំហែងនៅពេលសុំឈប់ពីការងារ
- ត្រូវបានប្រាប់មិនឱ្យចូលជាសមាជិកនៃសហជីពការងារ
- បញ្ហាទាក់ទងនឹងការងារផ្សេងៗទៀត